# ព្រះវិហារចាស់នៅវត្តល្វេ[1]

នៅក្នុងស្រុកកោះសូទិន ខេត្តកំពង់ចាម មានវត្តជាច្រើនបានកសាងឡើងនៅតាមបណ្តោយដងទន្លេមួយដែលអ្នកស្រុកហៅថា "ទន្លេតូច"។[2] បើរាប់ត្រួសៗវត្តបុរាណមួយចំនួននៅក្នុងតំបន់នេះមានដូចជា វត្តពង្រ វត្តជំនីក វត្តមហាលាភ និងវត្តល្វេជាដើម។ មកដល់បច្ចុប្បន្ន គេសង្កេតឃើញថាក្នុងវត្តទាំងនោះ ភាគច្រើននៅមានព្រះវិហារបុរាណដែលសេសសល់ពីការបំផ្លិចបំផ្លាញក្នុងសម័យសង្គ្រាម។ ជាក់ស្តែង វត្តល្វេស្ថិតនៅត្រើយម្ខាងនៃដងទន្លេតូច គឺជាវត្តមានព្រះវិហារចាស់មួយខ្នង មានគំនូរបុរាណយ៉ាងល្អគួរនៅលើហប់ខ្យល់ជុំវិញ។ ប៉ុន្តែបន្ទាប់ពីវត្តនេះបានកសាងព្រះវិហារធំថ្មីមួយទៀតកាលពីឆ្នាំ ២០០១ ព្រះវិហារចាស់ដែលនិយាយមកខាងលើ ហាក់ដូចជាត្រូវទុកចោល ពុំសូវមានការថែទាំ បោសសម្អាត ឬចូលទៅគោរពប្រតិបត្តិដូចបុរាណកាលឡើយ (រូបលេខ១)។



រូបលេខ១ សភាពខាងក្រៅនៃព្រះវិហារចាស់ក្នុងវត្តល្វេសព្វថ្ងៃ (ថតពីព្រះវិហារថ្មី)

[1] វត្តនេះមានឈ្មោះថ្មីទៀតហៅថា "វត្តរតនវង្សី"។

[2] ទន្លេតូច ហូរបែកពីទន្លេមេគង្គត្រង់ភាគខាងត្បូងទីរួមខេត្តកំពង់ចាម ភ្ជាប់ទៅទន្លេមេគង្គផ្នែកខាងក្រោមត្រង់ចំណុចខាងជើងអ្នកលឿង ខេត្តព្រៃវែង។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ព្រះវិហារចាស់នៅក្នុងវត្តល្វេ គឺជាប្រភេទព្រះវិហារបុរាណ ទំហំតូចល្មម សង់លើខឿន១ថ្នាក់ មានបណ្តោយប្រហែល២០ម៉ែត្រ និងទទឹងជាង១០ម៉ែត្រ។ នៅលើសសរខាងក្នុងជាប់នឹងបល្ល័ង្កព្រះដីវ៍ ឃើញមានចំណារមួយបន្ទាត់ខ្លី (រលុបចុងបន្ទាត់បន្តិច) មានសេចក្តីថា "ព្រះពុទ្ធស្សករាជ្យត្រូវសាស្នាអត្តិកត្តាកន្លងទៅបាន២៤៥៨" ពោលគឺត្រូវនឹងរវាងឆ្នាំ១៩១៥ ហើយដែលគេសន្និដ្ឋានថាជាឆ្នាំរៀបចំជួសជុល ឬរចនាក្បាច់ទឹបមាសក្នុងព្រះវិហារ។ មិនតែប៉ុណ្ណោះ បើតាមអ្នកស្រាវជ្រាវ *Danielle* និង *Dominique-Pieree Guéret* យល់ថាព្រះវិហារខាងលើ សង់ក្នុងចុងសតវត្សរ៍ទី១៩។[3] ទន្ទឹមនឹងនេះ បើផ្អែកតាមរូបថតឯកសាររបស់សាលាបារាំងចុងបូព៌ាប្រទេស (EFEO) ថតនៅក្នុងឆ្នាំ១៩២៩ ឃើញថាព្រះវិហារចាស់វត្តល្វេ គឺជាព្រះវិហារឈើ ពុំមែនជញ្ជាំងរៀបឥដ្ឋដូចសព្វថ្ងៃឡើយ ហើយការលម្អនៅលើហោជាងទាំងពីរហាក់នៅរក្សាទម្រង់ដើមទាំងស្រុង។ ប៉ុន្តែទោះជាយ៉ាងណាក្តី ចាស់ទុំខ្លះដំណាលថា ក្នុងសម័យសង្គ្រាម ព្រះវិហារចាស់វត្តល្វេនេះបានប្រើធ្វើជាកន្លែងព្យាបាលអ្នកជំងឺ ហើយវាយបំផ្លាញព្រះបដិមាព្រះដីវ៍ផង។

បច្ចុប្បន្នព្រះវិហារចាស់វត្តល្វេ គឺជាសំណង់បេតិកភណ្ឌមួយនៅក្នុងបរិវេណវត្តដែលមានដំបូលប្រក់ក្បឿងស្រកាលេញ បំពាក់ជហ្វាបួន ជញ្ជាំងរៀបឥដ្ឋបូកបាយអរ និងមានសសរឈើមូលចំនួន២៨ដើម។ ព្រះវិហារនេះមានទ្វារខាងមុខ២ និងខាងក្រោយ២។ ចំណែកឯជញ្ជាំងចំហៀងទាំងសងខាង មានបង្អួចសរុប១២ ហើយលើជញ្ជាំងខាងមុខ និងខាងក្រោយត្រង់ចន្លោះទ្វារ មានកូនបង្អួចម្ខាង១ដូចគ្នា។ នៅជ្រុងទាំងបួន មានបង្អួចបញ្ឆោត២ផងដែរ។ សន្ទឹកទ្វារ និងបង្អួចទាំងអស់ពុំមានក្បាច់លម្អអ្វីឡើយ ពោលគឺជាបន្ទះក្តារលាត ដែលទំនងជួសជុលរៀបចំនៅក្រោយសង្គ្រាម។ ប៉ុន្តែនៅផ្នែកខាងលើទ្វារ បង្អួចនីមួយៗមានក្បាច់លម្អរាងជាពាក់កណ្តាលរង្វង់ផ្កាប់លើស៊ុមទ្វារ និងបង្អួចទាំងនោះ (រូបលេខ២)។



*រូបលេខ២ លក្ខណៈព្រះវិហារមើលពីមុខ*

---

[3] Danielle & Dominique-Pieree Guéret 2017: 83

*អត្ថបទដោយ៖ ហៀន សុវណ្ណមរកត*

ដោយឡែកចំពោះរចនាសម្ព័ន្ធគ្រឿងបង្គុំផ្នែកខាងលើ គេឃើញសាងឡើងដោយមានស្លាបដំបូលជ្រាលចុះជាថ្នាក់ៗ លម្អដោយជហ្វាពីរនៅចុងមេដំបូលខាងមុខ ជហ្វាពីរទៀតនៅចុងមេដំបូលខាងក្រោយ ដូចព្រះវិហារបុរាណដទៃទៀតដែរ។ នៅតាមចុងចែងដំបូល លម្អដោយនាគចែង (រូបលេខ២៣) ហើយនៅតាមរងស្បូវជុំវិញ លម្អដោយក្បាច់កញ្ចាំង និងក្បាច់ផ្សេងៗទៀតឆ្លាក់ពីឈើបិទកញ្ចក់ (រូបលេខ២៤)។





**រូបលេខ២៣ ជហ្វា និងនាគចែង (ផ្នែកខាងក្រោយ)**    **រូបលេខ២៤ ក្បាច់លម្អលើរងស្បូវ**

ចំណែកការលម្អលើហោជាងព្រះវិហារចាស់វត្តល្វេ គេសង្កេតឃើញមានលក្ខណៈពុំដូចគ្នាឡើយ។ ហោជាងខាងកើត ឆ្លាក់ពីឈើក្នុងទម្រង់ជាក្បាច់ភ្ញីភ្ញើង ព័ទ្ធជុំវិញទេពមួយអង្គមានព្រះហត្ថ៤ គង់លើដំរីក្បាលបី (ដំរីឰរាវ័ត) និងមានទេវតាលេចចេញពីខ្សែក្បាច់ត្រឹមពាក់កណ្តាលខ្លួនប្រហែលម្ខាងៗ។ ថ្វីបើកេតនភណ្ឌខ្លះបាក់របេះបាត់ តែគេយល់ថាទេពអង្គនេះគឺជា "ព្រះឥន្ទ្រ" ដែលជាលោកបាលប្រចាំថែរក្សាទិសខាងកើត (រូបលេខ២៥-៦)។[4] ចំពោះហោជាងខាងលិច ឆ្លាក់ពីឈើជាក្បាច់ភ្ញីភ្ញើងដូចហោជាងខាងកើតដែរ តែនៅផ្នែកកណ្តាលគេឆ្លាក់រូបគ្រុឌ មានដៃទាំងពីរចាប់កន្ទុយនាគត្រដាងទៅលើ ជើងទាំងពីរជាន់លើក្បាលនាគ មានលំនាំស្រដៀងចម្លាក់គ្រុឌហែកនាគតាមប្រាសាទបុរាណ (រូបលេខ២៧-៨)។ ជាអកុស ស្នាដៃសិល្បៈលើហោជាងទាំងពីរបានពុករបេះខូច បាត់ផ្នែកខ្លះដោយអន្ទើ។ ប៉ុន្តែបើផ្ទៀងផ្ទាត់នឹងរូបថតឯកសារបារាំងថតឆ្នាំ១៩២៩ គេឃើញថាទឹកដៃសិល្បៈនៃក្បាច់រចនាហោជាងទាំងពីរមានលក្ខណៈវិចិត្រក្រៃលែង។

[4] ជី រដ្ឋា ២០០៧-២០០៨: ៧៨-៨១ និង ឈួន សុខខៃ ២០២២: ៥៣-៥៥

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ៥-៦ ហោជាងខាងកើត (រូបថត EFEO ឆ្នាំ១៩២៩) និងស្ថានភាពបច្ចុប្បន្ន



រូបលេខ៧-៨ ហោជាងខាងលិច (រូបថត EFEO ឆ្នាំ១៩២៩) និងស្ថានភាពបច្ចុប្បន្ន

នៅផ្នែកខាងក្នុងព្រះវិហារ គេសង់ឡើងដោយមានសសរឈើយ៉ាងប្រណីតចំនួន ៤ជួរ ទុកល្វែងគ្រឹះធំទូលាយមួយនៅកណ្ដាល អមដោយរបៀងសងខាង តែពុំមានបាំងសាចឡើយ ពោលគឺធ្វើជញ្ជាំងជិតជុំវិញតែម្ដង (រូបលេខ៩)។[5] ចំពោះសសរ (៤ដើមអមបល្ល័ង្កព្រះជីវ៍) និងគ្រឿងបង្គុំឈើនៅផ្នែកខាងលើដូចជា ធ្នឹម ផ្ទោង ផ្ទាន និងបង្កង់ សុទ្ធតែរចនាទឹបមាសទាំងអស់។ ប៉ុន្តែគួរឱ្យស្ដាយ សព្វថ្ងៃមានផ្នែកខ្លះត្រូវកណ្ដៀរចាប់ផ្ដើមស៊ីបំផ្លាញ និងពូនដីបន្តិចម្ដងៗ ទន្ទឹមគ្នានឹងការរបេះរបកក្បាច់ទឹបមាសទាំងនោះជាបណ្ដើរៗ (រូបលេខ១០)។ ចំណែកព្រះជីវ៍ក្នុងព្រះវិហារនេះ តម្កល់នៅលើបល្ល័ង្កយ៉ាងខ្ពស់មួយនៅចុងខាងលិចល្វែងគ្រឹះ តែជាព្រះជីវ៍ថ្មីកសាងឡើងនៅក្នុងឆ្នាំ១៩៨០។

[5] បើផ្អែកលើចំណារ តម្លៃសសរព្រះវិហារនេះមួយដើម ១០រៀល។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ៩ ផ្នែកខាងក្នុងព្រះវិហារ



រូបលេខ១០ ស្ថានភាពខ្វះនៃគ្រឿងបង្គុំខាងលើ

នៅផ្នែកខាងក្នុងព្រះវិហារបុរាណនេះដែរ ពុំឃើញមានគំនូរនៅលើជញ្ជាំងដូចព្រះវិហារផ្សេងទៀយ ពោលគឺទុកជាជញ្ជាំងលាត លាបពណ៌ស។ ប៉ុន្តែផ្នែកសំខាន់ៗដែលគេគូរគឺ សសរ ពិតាន និងហប់ខ្យល់។ នៅលើសសរទាំង២៤ដើម[6] ខាងមុខព្រះដីរ៍ក្រៅពីគូរលម្អជារូបនាគពេនព័ទ្ធចុះមក គេឃើញមានគូរតួអង្គក្នុងទេពកថាមួយចំនួននៅចន្លោះរង្វេលខ្លួននាគដូចជា ទេវតា យក្ស ហនុមាន អង្គទ គ្រុឌ កិន្នរ និងសត្វផ្សេងៗ។

គំនូរលើពិតាន (ពិតានឈើ) គេឃើញមានតែបួនផ្ទាំងប៉ុណ្ណោះ។ នៅចំពីលើព្រះដីរ៍ គេគូររូបពន្លឺឆព្វណ្ណរង្សីជារាងរង្វង់យ៉ាងធំ។ ចំណែកឯបីផ្ទាំងផ្សេងទៀត គេគូរជារូបព្រះអាទិត្យ ព្រះចន្ទ្រ និងទេវបុត្រ អមដោយរូបទេពនិករកាន់ផ្កាហោះហើរជុំវិញ។ រូបវង់ព្រះអាទិត្យ គេគូរបង្ហាញទេវបុត្រគង់លើរាជរថទឹមរាជសីហ៍ ហើយរូបវង់ព្រះចន្ទ្រគេគូរទេវបុត្រគង់រាជរថដែរ តែទឹមគោ ស្រដៀងនឹងគំនូរព្រះចន្ទ្រនៅលើពិតានឈើវត្តកណ្តាល ក្នុងស្រុកស្រីសន្ធរដែរ (រូបលេខ១១)។

ដោយឡែកនៅលើហប់ខ្យល់ ដែលជាបន្ទះការពារខ្យល់ និងភ្លៀងនៅចន្លោះធ្នឹមនិងពិតាន គេសង្កេតឃើញមានគំនូរបុរាណតូចៗគូរព័ទ្ធជុំវិញល្វែងគ្រឹះ ហើយពិបាកនឹងមើលផង (នៅទីខ្ពស់ហើយរលុប)។ ប៉ុន្តែបើពិនិត្យលម្អិត គេដឹងថាប្រធានបទគូរលើហប់ខ្យល់ព្រះវិហារចាស់វត្តល្វេគឺ រឿងពុទ្ធប្រវត្តិ (រូបលេខ១២) រឿងក្នុងជាតក (រូបលេខ១៣) និងរឿងជ័យទត្ត (រូបលេខ១៤) ដែលកម្រឃើញមានគូរនៅតាមព្រះវិហារផ្សេង។

---

[6] សសរ៤ ដើមអមបល្ល័ង្កព្រះដីរ៍លម្អដោយគំនូរបុក។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ១១ គំនូរព្រះអាទិត្យ ព្រះចន្ទ្រ និងទេពនិករគូរនៅលើពិតានខាងមុខព្រះដីវ៍



រូបលេខ១២ គំនូរពុទ្ធប្រវត្តិ "កាលព្រះអង្គផ្ចាញ់កូនស្រីមារទាំងបីនាក់"

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ១៣ គំនូរក្នុងតេមិយជាតក "កាលអាមាត្យយកពស់ទៅល្បងព្រះតេមិយ"



រូបលេខ១៤ គំនូរក្នុងរឿងជ័យទត្ត "កាលឥសីអុជធូបទៀនផ្សង"

សង្ខេបសេចក្តីមក ព្រះវិហារចាស់ក្នុងវត្តល្វេគឺជាសំណង់បេតិកភណ្ឌប្រកបដោយលក្ខណៈស្ថាបត្យកម្ម និងសិល្បៈបុរាណដ៏កម្រ។ ក្បាច់លម្អ និងគំនូរសាច់រឿងនានាក្នុងពុទ្ធប្រវត្តិ រឿងជាតក និងរឿងជ័យទត្តគូរនៅលើហប់ខ្យល់ គឺជាមូលដ្ឋានយ៉ាងសំខាន់សម្រាប់ការសិក្សាបន្ថែមទៅថ្ងៃខាងមុខ អំពីទំនាក់ទំនង និងតួនាទីសាច់រឿងព្រះពុទ្ធសាសនាក្នុងផ្នត់គំនិតខ្មែរ៕

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# ឯកសារយោង

ជី វង្ស

២០០៧-២០០៨, "ព្រះឥន្ទ្រនៅក្នុងអារ្យធម៌ខ្មែរ", *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ*, លេខ៣, ទំ.៧៨-៨១, Friend of Khmer Culture, ភ្នំពេញ

ឈួន សុខខៃ

២០២២, *វត្តរតនវង្សី ហៅវត្តល្វេ ស្រុកកោះសូទិន ខេត្តកំពង់ចាម*, សារណាបញ្ចប់បរិញ្ញាបត្របុរាណវិទ្យា, សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, ភ្នំពេញ

Danielle and Dominique-Pieree Guéret

2017, *The Khmer Pagoda,* KAM Edition

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត